សុន្ទរកថារបស់ **ឯកឧត្តម ហ៊ីដេហ៊ីសា ហូរីណូអ៊ុជិ** ឯកអគ្គរាជទូតវិសាមញ្ញ
និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
**២៥ វិច្ឆិកា ២០១៦**

- សូមគោរព **លោក អ៊ុខ ម៉ុឡា** នាយកប្រតិបត្តិនៃអង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍ
- សូមគោរព **លោក ខី សែត** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង
- សូមគោរព **លោក ហ៊ឹម សុផល** អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង
- សូមគោរព **វេជ្ជបណ្ឌិត ហុក គ្រី** ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិភ្នំស្រួច ខេត្តកំពង់ស្ពឺ
- សូមគោរព អស់លោក លោកស្រី!

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខានៅថ្ងៃនេះ លើកិច្ចសន្យាផ្តល់ជំនួយចំនួនបួនសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។

គម្រោងជំនួយទីមួយ ដែលមានថវិកាចំនួន៥៨,៨០០ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសិក្សាមួយខ្នងនៅសាលាបឋមសិក្សាឈើទាលជ្រំ ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ គម្រោងសាងសង់អគារសិក្សាថ្មីនេះ គឺជាគម្រោងលើកទី១២ហើយ ដែលយើងបានផ្តល់ជូនដល់ខេត្តពោធិ៍សាត់ តាមរយៈជំនួយគូសាណូណិ។ គម្រោងនេះត្រូវបានរំពឹងថា នឹងជួយកែលម្អបរិស្ថាននៃការអប់រំអោយកាន់តែល្អប្រសើរ ដល់សិស្សានុសិស្សប្រមាណជា ២២០នាក់។

គម្រោងជំនួយទីពីរ ដែលមានថវិកាចំនួន៨១,៨១៨ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសិក្សាមួយខ្នងនៅសាលាបឋមសិក្សាបឹងស្នួល ក្នុងស្រុកបវេល ខេត្តបាត់ដំបង។ គម្រោងសាងសង់អគារសិក្សានេះ គឺជាគម្រោងលើកទី៩ហើយ ដែលយើងបានផ្តល់ជូនដល់ខេត្តបាត់ដំបងក្រោមជំនួយគូសាណូណិ ហើយគម្រោងនេះ ត្រូវបានរំពឹងថា នឹងជួយកែលម្អបរិស្ថាននៃការអប់រំដល់សិស្សានុសិស្សប្រមាណជា ២៣០ នាក់។

គម្រោងជំនួយទីបី ដែលមានថវិកាចំនួន៨២,៣៥៥ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សាឃ្លាំង ក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង។ គម្រោងសាងសង់អគារសិក្សាថ្មីនេះ

គឺជាគម្រោងលើកទី១០ហើយ ដែលយើងបានផ្តល់ជូនដល់ខេត្តព្រៃវែងក្រោមជំនួយគូសាណូណិ។ គម្រោងនេះត្រូវបានរំពឹងថា នឹងជួយកែលម្អបរិស្ថាននៃការអប់រំដល់សិស្សានុសិស្សប្រមាណជា ៦១០នាក់ អោយកាន់ល្អប្រសើរជាងមុនមិនខាន។

គម្រោងជំនួយទីបួន ដែលមានថវិកាចំនួន ៨២,៣៤១ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសម្ភព និងរោគស្រ្តី នៅក្នុងមន្ទីរពេទ្យបង្អែកត្រពាំងក្រឡឹង ខេត្តកំពង់ស្ពឺ។ គម្រោងទី៤នេះ គឺជាគម្រោងគូសាណូណិផ្នែកសុខាភិបាលលើកទី៦ហើយ ដែលបានផ្តល់ជូនដល់ខេត្តកំពង់ស្ពឺ។ អគារសម្ភព និងរោគស្រ្តីថ្មីនេះនឹងជួយថែទាំសុខភាពមាតា និងទារកអោយកាន់តែល្អប្រសើរ នៅមន្ទីរពេទ្យបង្អែកនេះ ព្រមទាំងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ស្ត្រី និងកុមារប្រមាណជា ៧,២០០នាក់ផងដែរ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អគារសិក្សា និងអគារមន្ទីរពេទ្យទាំងអស់ ដែលត្រូវបានផ្តល់ជូនតាមរយៈគម្រោងទាំងនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវគង់វង្សយូរអង្វែង ដើម្បីអោយសិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងអ្នកជម្ងឺកាន់តែច្រើន អាចប្រើប្រាស់ និងទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះតាមដែលអាចទៅបាន។ ខ្ញុំសង្ឃឹមថា គម្រោងទាំងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណ!**